អាជ្ញាធរជាតិអប្សរា
APSARA

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៩០៨/២៤ រ.ប. សបក

## សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់សាធារណមតិ មេត្តាជ្រាបថា កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានចេញសេចក្តីប្រកាសព័ត៌មានសម្តែងការព្រួយបារម្ភលើការតាំងទីលំនៅថ្មីដោយបង្ខំ របស់ប្រជាជនរស់នៅតំបន់អង្គរ ដើម្បីកិច្ចអភិរក្ស។

ពាក់ព័ន្ធនឹងការលើកឡើងរបស់អ្នកជំនាញការខាងលើ អាជ្ញាធរជាតិអប្សរាសូមធ្វើការបញ្ជាក់ជូនដូចខាងក្រោមៈ

១- អាជ្ញាធរជាតិអប្សរា ជានិច្ចកាលរមែងបំពេញកិច្ចការងារក្នុងការលើកកម្ពស់ និងការគោរពសិទ្ធិមនុស្សស្របតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលកម្ពុជា។ ក្នុងរយៈកាល៣០ឆ្នាំកន្លងមកនេះ អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ខ្ពស់លើកិច្ចការអភិវឌ្ឍន៍ប្រកបដោយចីរភាពសហគមន៍ និងការរស់នៅរបស់ប្រជាពលរដ្ឋចំនួន១១២ភូមិ ដែលរស់នៅយូរលង់ណាស់មកហើយ ក្នុងតំបន់រមណីយដ្ឋានអង្គរ។ បច្ចុប្បន្ន បុគ្គលិកចំនួន ៧៤% ដែលកំពុងបំពេញការងារនៅក្នុងអាជ្ញាធរជាតិអប្សរា គឺជាប្រជាពលរដ្ឋរស់នៅក្នុងតំបន់អង្គរ។

២- ក្នុងនាមជាស្ថាប័នទទួលបន្ទុកកិច្ចការអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាជានិច្ចកាលមានកាតព្វកិច្ចគោរព និងអនុវត្តទៅតាមខ្លឹមសារចែងក្នុងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធកិច្ចការពារបេតិកភណ្ឌវប្បធម៌ ជាពិសេសគោលការណ៍ប្រតិបត្តិសម្រាប់ការអនុវត្តអនុសញ្ញាស្តីពីបេតិកភណ្ឌពិភពលោក។

៣- អាជ្ញាធរជាតិអប្សរាមានការសោកស្តាយជាខ្លាំង ដោយអ្នករាយការណ៍ពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្សបានទទួលនូវរបាយការណ៍មួយចំនួន ដែលមិនបានឆ្លុះបញ្ចាំង ក៏ដូចជាមិនបានស្វែងយល់ព័ត៌មានពិត និងសភាពជាក់ស្តែង នៅក្នុងរមណីយដ្ឋានអង្គរ និងតំបន់ពាក់ព័ន្ធ។

៤- អាជ្ញាធរជាតិអប្សរា ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ជាពិសេសចំពោះប្រជាជន ដែលបានតាំងទីលំនៅមិនសមស្របមួយចំនួនក្នុងតំបន់ការពារ ហើយដែលបានស្ម័គ្រចិត្តទៅតាំងទីលំនៅថ្មី តាមរយៈការផ្តល់នូវកិច្ចគាំពារ ដូចជាគោលការណ៍ទទួលកម្មសិទ្ធិដីធ្លីស្របច្បាប់ គោលនយោបាយគាំពារសង្គមរយៈពេល១០ឆ្នាំ និងការគាំពារជាច្រើនផ្សេងទៀត ដើម្បីលើកកម្ពស់សេដ្ឋកិច្ចសង្គមដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

៥- ជាមួយគ្នានេះ បញ្ហាដែលបានលើកឡើង ត្រូវបានយកមកពិភាក្សាយ៉ាងលម្អិត ពីអ្នកជំនាញការជាតិ និងអន្តរជាតិក្នុងកិច្ចប្រជុំបច្ចេកទេសនាពេលកន្លងមក និងជាពិសេសក្នុងកិច្ចប្រជុំលើកទី៣៩ និងពេញអង្គលើកទី៣១ នៃអាយស៊ីស៊ី-អង្គរ/សំបូរព្រៃគុក ប្រព្រឹត្តទៅពីថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីផ្តល់ធាតុចូលបន្ថែមលើការរក្សាតុល្យភាពរវាងកិច្ចអភិរក្ស និងការអភិវឌ្ឍន៍សហគមន៍ប្រជាជន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណមតិជាទូទៅ មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

សៀមរាប ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋានៈ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province